**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសុខាភិបាល**

# ផែនការយុទ្ធសាស្ត្រជាតិ

សម្រាប់

## ការត្រួតពិនិត្យការចម្លងរោគក្នុងមូលដ្ឋានសុខាភិបាល

**ចាប់ពីឆ្នាំ ២០១១-២០១៥**

**២០ ខែ កក្កដា ឆ្នាំ ២០១០**

# តារាងមាតិកា

តារាងមាតិកា ..... ii
អារម្ភកថា ..... iv
សេចក្តីថ្លែងអំណរគុណ ..... v
សេចក្តីផ្តើមនៃផែនការយុទ្ធសាស្ត្រ ..... 1
សាវតារ ..... 1
គោលបំណង ..... 2
គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិ ..... 2
ការរៀបចំផែនការយុទ្ធសាស្ត្រ ..... 3
១. ការគ្រប់គ្រង និងការរៀបចំកម្មវិធីត្រួតពិនិត្យការចម្លងរោគ ..... 4
១.១ គោលដៅយុទ្ធសាស្ត្រ ..... 4
១.២ សកម្មភាពដែលត្រូវអនុវត្ត ..... 4
២. ការអភិវឌ្ឍធនធានមនុស្ស និង ការបណ្តុះបណ្តាល ..... 5
២.១ គោលដៅយុទ្ធសាស្ត្រ ..... 5
២.២ សកម្មភាពដែលត្រូវអនុវត្ត ..... 5
៣. គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ ..... 6
៣.១ គោលដៅយុទ្ធសាស្ត្រ ..... 6
៣.២ សកម្មភាពដែលត្រូវអនុវត្ត ..... 6
៤. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បរិក្ខារនិងសម្ភារៈត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ ..... 7
៤.១ គោលដៅយុទ្ធសាស្ត្រ ..... 7
៤.២ សកម្មភាពដែលត្រូវអនុវត្ត ..... 7
៥. បរិស្ថាននៅក្នុងមូលដ្ឋានសុខាភិបាល ..... 8
៥.១ គោលដៅយុទ្ធសាស្ត្រ ..... 8
៥.២ សកម្មភាពដែលត្រូវអនុវត្ត ..... 8
៦. ការគ្រប់គ្រងសំណល់នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន ..... 9
៦.១ គោលដៅយុទ្ធសាស្ត្រ ..... 9
៦.២ សកម្មភាពដែលត្រូវអនុវត្ត ..... 9
៧. សហប្រតិបត្តិការ និង ការធ្វើធំនាក់ទំនង ..... 10

៧.១ គោលដៅយុទ្ធសាស្ត្រ ........ 10
៧.២ សកម្មភាពដែលត្រូវអនុវត្ត ........ 10
**៨. ការត្រួតពិនិត្យតាមដាន និង ការវាយតម្លៃ** ........ 10
៨.១ គោលដៅយុទ្ធសាស្ត្រ ........ 10
៨.២ សកម្មភាពដែលត្រូវអនុវត្ត ........ 10
**៩. ការអង្កេតឃ្លាំមើល** ........ 11
៩.១ គោលដៅយុទ្ធសាស្ត្រ ........ 11
៩.២ សកម្មភាពដែលត្រូវអនុវត្ត ........ 11
**១០. សេវារោគវិនិច្ឆ័យអតិសុខុមជីវសាស្ត្រ** ........ 12
១០.១ គោលដៅយុទ្ធសាស្ត្រ ........ 12
១០.២ សកម្មភាពដែលត្រូវអនុវត្ត ........ 12
**១១. ការប្រើឱសថអង់ទីប៊ីយ៉ូទិកដោយប្រុងប្រយ័ត្ន** ........ 12
១១.១ គោលដៅយុទ្ធសាស្ត្រ ........ 12
១១.២ សកម្មភាពដែលត្រូវអនុវត្ត ........ 12
**១២. ការស្រាវជ្រាវ និងការអភិវឌ្ឍ** ........ 13
១២.១ គោលដៅយុទ្ធសាស្ត្រ ........ 13
១២.២ សកម្មភាពដែលត្រូវអនុវត្ត ........ 13
**១៣. សុខភាព និង សុវត្ថិភាពការងារ** ........ 13
១៣.១ គោលដៅយុទ្ធសាស្ត្រ ........ 13
១៣.២ សកម្មភាពដែលត្រូវអនុវត្ត ........ 13
**១៤. ហិរញ្ញប្បទាន និងនិរន្តរភាពនៃសកម្មភាពត្រួតពិនិត្យការចម្លងរោគ** ........ 14
១៤.១ គោលដៅយុទ្ធសាស្ត្រ ........ 14
១៤.២ សកម្មភាពដែលត្រូវអនុវត្ត ........ 14
១៥.១ គោលដៅយុទ្ធសាស្ត្រ ........ 14
១៥.២ សកម្មភាពដែលត្រូវអនុវត្ត ........ 14
**សកម្មភាពអទិភាពនៃផែនការយុទ្ធសាស្ត្រត្រួតពិនិត្យការចម្លងរោគ** ........ 15

---------------------------

# អារម្ភកថា

ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់ការត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានសុខាភិបាលពីឆ្នាំ ២០១១-២០១៥ ដើម្បីឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិក សម្រាប់ជំងឺឆ្លងកើតឡើងរបស់អង្គការសុខភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ដោយមានការចូលរួមសហការពីភាគីពាក់ព័ន្ធជាច្រើន ដែលធ្វើការនៅក្នុងការលើកកម្ពស់ការត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានព្យាបាល និងថែទាំសុខភាពនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ យើងបានសង្កេតឃើញមានការកើនឡើងនូវលំហូរធនធានទៅក្នុងការងារត្រួតពិនិត្យការចម្លងរោគតាមរយៈអង្គការមិនមែនរដ្ឋាភិបាល និង ភ្នាក់ងារសហប្រជាជាតិមួយចំនួនប៉ុន្តែការគាំទ្រនេះនៅមិនទាន់មានផែនការយុទ្ធសាស្ត្រនៅឡើយដែលជាហេតុនាំឱ្យមានការតម្រង់ទិសធនធានមិនបានត្រឹមត្រូវដល់ផ្នែកដែលមិនមែនអាទិភាពនានាបណ្តាលឱ្យ ការអនុវត្តការត្រួតពិនិត្យការចម្លងរោគមិនបានល្អនៅក្នុងមូលដ្ឋានសុខាភិបាលឡើយ។

ផែនការយុទ្ធសាស្ត្រនេះមានសារសំខាន់សម្រាប់ក្រសួងសុខាភិបាល ផ្តល់នូវយន្តការមួយដោះស្រាយបញ្ហាប្រឈមនឹងជំងឺឆ្លងដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាល និងជួយគាំទ្រការងារធ្វើផែនការសកម្មភាព នឹងព្រមទាំងសមត្ថភាពឆ្លើយតបរបស់មូលដ្ឋានគ្រប់លំដាប់ថ្នាក់ដោយជាមួយដៃគូអភិវឌ្ឍនានា។ ផែនការយុទ្ធសាស្ត្រនេះគឺ ជាគន្លឹះមួយយ៉ាងសំខាន់ក្នុងការតម្រឹមតម្រង់និយ័តកម្មសុខភាពអន្តរជាតិ និង អនុវត្តផែនការយុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិកសម្រាប់ជំងឺឆ្លងកើតឡើងរយៈពេលប្រាំឆ្នាំបន្ទាប់គឺ ២០១១-២០១៥។ មន្ទីរពេទ្យជាតិ-មជ្ឈមណ្ឌលជាតិ មន្ទីរសុខាភិបាលរាជធានី-ខេត្ត. ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវតែធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំនីមួយៗ ដើម្បីឱ្យការអនុវត្តបានសម្រេចនូវគោលដៅរបស់ក្រសួងសុខាភិបាល។

ក្រសួងសូមថ្លែងអំណរគុណចំពោះការគាំទ្រ និង ការរួមចំណែកដ៏មានតម្លៃរបស់អង្គភាពនានា នាយកដ្ឋានក្រោមឱវាទក្រសួងសុខាភិបាល រួមទាំងអង្គការដៃគូអភិវឌ្ឍនានា ជាពិសេសអង្គការៈ WHO; URC; OPTIONS, VSO, GTZ, JICA, RHAC, RACHA MSF and UNICEF ...ដែលបានជួយឧបត្ថម្ភគាំទ្រនូវផែនការនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

សាស្ត្រាចារ្យ. អេង ហួត

រដ្ឋលេខាធិការក្រសួងសុខាភិបាល

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក-លោកស្រី និង អង្គការដែលបាន ជួយគាំទ្រទាំងផ្នែកសម្ភារៈ និង បច្ចេកទេស និង ការចូលរួមបង្កើត និង បញ្ចប់ផែនការយុទ្ធសាស្ត្រជាតិនេះ

**ក្រុមប្រឹក្សាបច្ចេកទេសនៃក្រសួងសុខាភិបាលៈ**

| | | |
|---|---|---|
| ឯ.ឧ. សាស្ត្រាចារ្យ | អេង ហួត | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ឯ.ឧ. សាស្ត្រាចារ្យ | ធា គ្រុយ | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ឯ.ឧ. សាស្ត្រាចារ្យ | ហេង តៃគ្រី | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ឯ.ឧ. វេជ្ជបណ្ឌិត | ទេព លន់ | អគ្គនាយកបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល |
| លោកវេជ្ជបណ្ឌិត. | ជី មានហៀ | អគ្គនាយករងបច្ចេកទេសសុខាភិបាល |
| លោកសាស្ត្រាចារ្យ | គុំ កាណាល់ | ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| លោកវេជ្ជបណ្ឌិត. | សុខ ទូច | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| លោកវេជ្ជបណ្ឌិត. | សាន់ សារី | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត. | ឡូ វ៉ាសនាគីរី | ប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |

**ក្រុមការងារបច្ចេកទេសរៀបចំ និងក្រុមជំនាញការនៃអង្គការដៃគូអភិវឌ្ឍនានាជួយផ្តល់ប្រឹក្សាៈ**

| | | |
|---|---|---|
| លោកវេជ្ជបណ្ឌិត. | សុខ ស្រ៊ុន | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ និងជាប្រធានក្រុមរៀបចំផែនការយុទ្ធសាស្ត្រ |
| លោកវេជ្ជបណ្ឌិត. | លី សូវ៉ាន់ | អនុប្រធាននាយកដ្ឋានប្រយុទ្ធជំងឺឆ្លង និងជាអនុប្រធានក្រុមរៀបចំផែនការយុទ្ធសាស្ត្រ |
| ក.វេជ្ជបណ្ឌិត | ស៊ឹម សន្សំ | ជំនួយក្រុមការងារត្រួតពិនិត្យការចម្លងរោគ នៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកសាស្ត្រាចារ្យ | ឈួយ ម៉េង | អនុប្រធានការិយាល័យបច្ចេកទេស នៃមន្ទីរពេទ្យកាល់ម៉ែត |
| លោកសាស្ត្រាចារ្យ | អ៊ុំ សុខុម | នាយករងម.ប្រយុទ្ធនឹងជំងឺអេដស៍-សើស្បែកនិងកាមរោគ |
| លោកវេជ្ជបណ្ឌិត. | សុខ សុគន្ធ | នាយកមន្ទីរ មន្ទីរសុខាភិបាលរាជធានី |
| លោកវេជ្ជបណ្ឌិត. | ហេង ញឹ | ប្រធានមន្ទីរសុខាភិបាល ស្ទឹងត្រែង |
| លោកវេជ្ជបណ្ឌិត. | ជា ហ៊ុច | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត. | លឹម កាំងអៀង | ប្រធានមន្ទីរសុខាភិបាល ខេត្តកំពត |
| លោកវេជ្ជបណ្ឌិត. | ញឹក ប៊ុនឈុប | ប្រធានមន្ទីរសុខាភិបាល ខេត្តបាត់ដំបង |
| លោកឱសថការី. | តឹក ឡេងស៊ឺ | នាយកសាលា ស្ទឹងត្រែង |
| លោកវេជ្ជបណ្ឌិត | ស្វាយ សារ៉ាត | អនុប្រធានកម្មវិធីពង្រីកការចាក់ថ្នាំបង្ការ |
| លោកវេជ្ជបណ្ឌិត. | សេក សំប៊ុន | នាយករងនៃមន្ទីរពេទ្យព្រះកុសុមៈ |
| លោកវេជ្ជបណ្ឌិត. | ព្រហ្ម ផានិត | អនុប្រធានការិយាល័យបច្ចេកទេសនៃ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត |
| លោកវេជ្ជបណ្ឌិត. | ឆឹង យ៉ៅយ៉េន | អនុប្រធានមន្ទីរពេទ្យ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត |
| លោកវេជ្ជបណ្ឌិត. | ម៉ម វិទ្យារិទ្ធ | ប្រធានបច្ចេកទេស នៃមន្ទីរពេទ្យកុមារជាតិ |
| លោកវេជ្ជបណ្ឌិត. | ចាន់ សារី | ប្រធានការិយាល័យបច្ចេកទេស នៃមន្ទីរពេទ្យគន្ធបុប្ផា |
| លោកវេជ្ជបណ្ឌិត. | អំណត់ ភក្តី | ប្រធានការិយាល័យសិក្សា នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| លោកទន្តបណ្ឌិត. | ហេង សុបញ្ញា | ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យទន្តសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| លោកឱសថការី. | ថន ខៃលី | អនុប្រធានឃ្លាំងឱសថកណ្តាល |
| លោកវេជ្ជបណ្ឌិត. | សុត វុទ្ធី | អនុប្រធានវិទ្យាស្ថានស្រាវជ្រាវសុខភាពសាធារណៈ |
| លោកវេជ្ជបណ្ឌិត. | អ៊ុង ថុល | អនុប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក |

| | | |
|---|---|---|
| លោកវេជ្ជបណ្ឌិត. | ជី ស៊ីវុទ្ធី | ប្រធានការិយាល័យសេវាមន្ទីរពេទ្យ នៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកស្រីវេជ្ជបណ្ឌិត | ជន ស៊ីនួន | ប្រធានការិយាល័យធានាគុណភាព នៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត | យូ សុផាត | ប្រធានផ្នែកវះកាត់ នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក |
| លោកវេជ្ជបណ្ឌិត | ឈរ ណារ៉េត | ប្រធានផ្នែកសង្គ្រោះបន្ទាន់ នៃមន្ទីរពេទ្យកាល់ម៉ែត |
| លោកស្រីឱសថការី | សំ សុភាព | ប្រធានការិយាល័យមន្ទីរពិសោធន៍ នៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកស្រីវេជ្ជបណ្ឌិត | ព្រំ ឆោមសាយឿន | ប្រធានផ្នែកមន្ទីរពេទ្យ នៃមជ្ឈមណ្ឌលកំចាត់រោគរបេង និងហង់សិន |
| លោកឱសថការី. | ឈាង សេនា | អនុប្រធានមន្ទីរសុខាភិបាល ខេត្តកំពង់ចាម |
| លោកវេជ្ជបណ្ឌិត | សេង សុផារុន | អនុប្រធានមន្ទីរសុខាភិបាល ខេត្តកំពង់ចាម |
| លោកវេជ្ជបណ្ឌិត | សេង ដារ៉ាក្រពុំ | អនុប្រធានសាលាពេទ្យ ខេត្តកំពង់ចាម |
| លោកវេជ្ជបណ្ឌិត | សុខ ចាន់ចុល | នាយករង មន្ទីរសុខាភិបាលស្ទឹងត្រែង |
| លោក | កុយ វីរិយ៉ា | ប្រធានការិយាល័យគិលានុបដ្ឋាក និងឆ្មប នាយកដ្ឋានមន្ទីរពេទ្យ |
| លោកស្រី | ហែម ណារី | អនុការិយាល័យគិលានុបដ្ឋាក និងឆ្មប នាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត | ភី រដ្ឋាយ៉ាន់ | អនុប្រធានការិយាល័យសេវាមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត | សោម សីហារ័ត្ន | អនុប្រធានការិយាល័យនិយ័តកម្ម និង ក្រមសីលធម៌ |
| លោកឱសថបណ្ឌិត. | វឿង វីរៈ | អនុប្រធានការិយាល័យ ការិយាល័យធានាគុណភាព |
| លោកស្រីវេជ្ជបណ្ឌិត | សូ ណាត្រី | ប្រធានក្រុមក្រុមត្រួតពិនិត្យការចម្លងរោគនៃ នាយកដ្ឋានមន្ទីរពេទ្យ |
| ក.ឱសថការីមធ្យម | អ៊ុក រមនា | ប្រធានក្រុមការងារគ្រប់គ្រងសំណល់ នៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត | ស៊ិន ទូច | ប្រធានក្រុមប្រើប្រាស់ឱសថសមស្របនៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត | ធន សេងអាន | ប្រធានក្រុមការងារចាក់ថ្នាំមានសុវត្ថិភាព នៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត | ជូ សុវត្ថា | អនុប្រធានក្រុមក្រុមប្រើប្រាស់ឱសថសមស្របនៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកស្រីវេជ្ជបណ្ឌិត | អ៊ូច សិរី | អនុប្រធានក្រុមត្រួតពិនិត្យការចម្លងរោគនៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកស្រីគ្រូពេទ្យ | ទេព ចិន្តា | អនុប្រធានក្រុមការងារគ្រប់គ្រងសំណល់នៃនាយកដ្ឋានមន្ទីរពេទ្យ |
| លោកវេជ្ជបណ្ឌិត | អ៊ុំ ផវិន្ត | មន្ត្រីបច្ចេកទេសនៃ អង្គការ យូ អ ស៊ី |
| លោកវេជ្ជបណ្ឌិត | ជា ណូរ៉ា | មន្ត្រីបច្ចេកទេសត្រួតពិនិត្យការចម្លងរោគ-ប្រព័ន្ធតាមដានជំងឺ WHO |
| លោកបណ្ឌិត | ម៉ូហាមេដ ណាសៀរ ហាសាន់ | វិស្វករផ្នែកបរិស្ថាននៃ អង្គការសុខភាពពិភពលោក |
| លោកស្រីវេជ្ជបណ្ឌិត | Magaret Mac Guinness | មន្ត្រីបច្ចេកទេស អង្គការសុខភាពពិភពលោក |
| លោកវេជ្ជបណ្ឌិត | នីម៉ា អាស្គារី | ជំនាញការខាងសុខភាពសាធារណៈ អង្គការសុខភាពពិភពលោក |
| លោកបណ្ឌិត | Sergey Eremin | ជំនាញការខាងសុខភាពសាធារណៈអង្គការសុខភាពពិភពលោក |
| លោកស្រីបណ្ឌិត | Carmem Lucia | ជំនាញការខាងសុខភាពសាធារណៈអង្គការសុខភាពពិភពលោក |
| លោកស្រីវេជ្ជបណ្ឌិត | ហ្វ្រាន សេស ដេលី | ទីប្រឹក្សានៃអង្គការ យូ អ ស៊ី |
| លោកស្រីបណ្ឌិត | Harriet Stanley | នាយកកម្មវិធីនៃអង្គការ OPTION |
| លោកស្រី | Joan Venghaus | ទីប្រឹក្សាគ្លីនីក នៃអង្គការ OPTION |
| លោកស្រី | Thou Kagnabelle | Training officer OPTIONS RMMP |
| លោក | ហ៊ី ឆៃលី | Program Support US CDC |
| លោកស្រីវេជ្ជបណ្ឌិត | មាត សុភាព | Ass Team Leader RACHA |
| លោកវេជ្ជបណ្ឌិត | ឆោម រ៉ាដា | Deputy Program Coordinator GTZ |
| លោកវេជ្ជបណ្ឌិត | ហ៊ុយ បន្ទូល | Center Manager BB MSIC Clinic |
| លោកស្រី | Emily Holtmaat | Nursing Advisor VSO RH/VSO |
| លោកស្រី | Janice Hay | Nursing Advisor VSO Banteay Meanchey |

# សេចក្តីផ្តើមនៃផែនការយុទ្ធសាស្ត្រ

## សាវតារ

ដូចមានបញ្ជាក់នៅក្នុងគោលនយោបាយជាតិ ស្តីពីការត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេស កម្ពុជាស្រាប់ បញ្ហាការចម្លងរោគដែលពាក់ព័ន្ធនឹងការថែទាំសុខភាពគឺជាបញ្ហាប្រឈមមួយ និង ជាកង្វល់ចម្បងមួយនៃការថែទាំសុខភាពនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាក្នុងពិភពលោកដែរ។ ការចម្លងរោគដែលពាក់ព័ន្ធនឹងការថែទាំសុខភាព បង្កឡើងដោយអតិសុខុមប្រាណតូចៗជាច្រើន ព្រមទាំងទាក់ទងនឹងការថែទាំវេជ្ជសាស្ត្រ និងការព្យាបាល។ ការសិក្សាជាច្រើនបង្ហាញថា ការចម្លងរោគដែលពាក់ព័ន្ធនឹងការថែទាំសុខភាព ធ្វើឱ្យមរណភាពកើនឡើង, ធ្វើឱ្យការស្នាក់នៅក្នុងមន្ទីរពេទ្យកាន់តែយូរ, និងបង្កើនការប្រើប្រាស់ឱសថ អង់ទីប៊ីយ៉ូទិក និងភាពស៊ាំរបស់មេរោគជាមួយអង់ទីប៊ីយ៉ូទិក ក៏ដូចជាការចំណាយក្នុងមន្ទីរពេទ្យកាន់តែច្រើនឡើង។ ជាមួយនឹងការកើតឡើងនូវភាពស៊ាំរបស់មេរោគ ជាមួយអង់ទីប៊ីយ៉ូទិក ឬការកើតឡើងនូវមេរោគថ្មីៗ ដូចជាជំងឺសារ, ផ្តាសាយបក្សី A/H5N1 ការចម្លងរោគដែលពាក់ព័ន្ធនឹងការថែទាំសុខភាពនៅតែជាគ្រោះថ្នាក់ដ៏លំបាកមួយ សូម្បីតែនៅក្នុងប្រទេសអភិវឌ្ឍក៏ដូច្នោះដែរ។ អត្រាជាមធ្យមនៃការចម្លងរោគដែល ពាក់ព័ន្ធនឹងការថែទាំសុខភាពគឺ ៥-១០% នៅក្នុងប្រទេសអភិវឌ្ឍ ប៉ុន្តែអត្រានេះអាចឈាន ដល់កម្រិតខ្ពស់ ២៥% នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ពី ៥-១០% នៃការចម្លងរោគដែល ពាក់ព័ន្ធនឹងការថែទាំសុខភាព បង្កឱ្យមានការផ្ទុះ ជំងឺនៅក្នុងមន្ទីរពេទ្យ។

បច្ចុប្បន្នការចម្លងរោគដែលពាក់ព័ន្ធនឹងការថែទាំសុខភាព គឺមានលក្ខណៈខ្លាំងក្លាហើយ ក្រសួងសុខាភិបាល និងអ្នកគ្រប់គ្រងមន្ទីរពេទ្យបានសំដែងនូវការព្រួយបារម្ភអំពីបញ្ហាថែទាំសុខភាពដែល កំពុងតែកើនឡើងនេះ។

ចាប់តាំងពីឆ្នាំ១៩៩៣មក មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក និងក្រសួងសុខាភិបាលបាន:

១. បង្កើតគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យការចម្លងរោគក្នុងមន្ទីរពេទ្យ ប៉ុន្តែផ្តោតតែទៅលើផ្នែកសម្ភព និងរោគស្ត្រីប៉ុណ្ណោះ ដោយមិនបានផ្តោតទៅលើការអនុវត្តការត្រួតពិនិត្យការចម្លងរោគទូទៅនោះទេ។

២. ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលដើម្បីពង្រឹងចំណេះដឹង និងជំនាញស្តីពីការត្រួតពិនិត្យការចម្លងរោគសម្រាប់ការឆ្លងជំងឺផ្លូវដង្ហើមស្រួច (H5N1) ក៏ដូចជា សុវត្ថិភាពនៃការចាក់ថ្នាំ។

៣. សេចក្តីព្រាងគោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ ដែលឥឡូវនេះកំពុងត្រូវបានមកប្រែជាភាសាខ្មែរ។

៤. គោលនយោបាយជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគដែលទើបអនុម័តក្នុងពេលថ្មីៗនេះ។

ប្រព័ន្ធត្រួតពិនិត្យការចម្លងរោគនៅគ្រប់កម្រិតកំពុងមានភាពប្រសើរឡើងបន្តិចម្តងៗ។ វឌ្ឍនភាព យឺតៗនេះ គឺដោយសារតែកង្វះខាតបុគ្គលិកដែលមានចំណេះដឹង និងជំនាញខាងការត្រួតពិនិត្យការចម្លងរោគ។ បន្ថែមពីលើនេះ ប្រធានមន្ទីរពេទ្យជាច្រើន និងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ក៏ខ្វះខាតចំណេះដឹងអំពីសកម្មភាពត្រួតពិនិត្យការចម្លងរោគផង ដែរ។

នៅឆ្នាំ២០០៩ អង្គការសុខភាពពិភពលោកជាមួយក្រសួងសុខាភិបាលកម្ពុជា បានរៀបចំគោលនយោបាយ ជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ ដោយផ្តោតទៅលើសកម្មភាពអាទិភាពជាអានុសាសន៍ ដែលរួមចំណែកដល់ ការអភិវឌ្ឍស្ថានភាពត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល មានគោលបំណងលើកកម្ពស់ និងពង្រឹងការងារត្រួតពិនិត្យការចម្លងរោគ នៅក្នុងប្រទេស ហើយក្រុមការងារត្រួតពិនិត្យការចម្លងរោគនៅក្នុងនាយកដ្ឋានមន្ទីរពេទ្យ ដោយអនុវត្តតាម ដំបូន្មានពីគណៈកម្មការ ដឹកនាំ មានគម្រោងរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយមួយសម្រាប់ការ ត្រួតពិនិត្យការចម្លងរោគពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥ និងរៀបចំផែនការសកម្មភាពជាតិទូលំទូលាយមួយ សម្រាប់ការត្រួតពិនិត្យការចម្លងរោគឆ្នាំ ២០១០-២០១១។

## គោលបំណង

ការត្រួតពិនិត្យការចម្លងរោគដើរតួនាទីយ៉ាងសំខាន់នៅក្នុងការថែទាំ និងការព្យាបាលអ្នកជំងឺនៅក្នុង មូលដ្ឋានថែទាំសុខាភិបាល។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានថែទាំសុខាភិបាល កម្ពុជាឆ្នាំ ២០១០-២០១៥ ត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវរចនាសម្ព័ន្ធមួយសម្រាប់អនុវត្ត សកម្មភាពជាអាទិភាព សម្រាប់ពង្រឹងការត្រួតពិនិត្យការចម្លងរោគ ដែលមានចែងនៅក្នុងគោលនយោបាយជាតិស្តីពីការត្រួតពិនិត្យការចម្លង រោគរបស់កម្ពុជា។

គោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិ គឺដើម្បីធានាដល់ការផ្តល់ការត្រួតពិនិត្យការចម្លងរោគ ប្រកបដោយ គុណភាព, ប្រសិទ្ធភាព, ប្រសិទ្ធផល, អាចមកប្រើប្រាស់បាន, សមធម៌ និងមានគុណតម្លៃសមរម្យ អាចទទួលយកបាន នៅក្នុងមូលដ្ឋានថែទាំសុខាភិបាលសម្រាប់ប្រជាជនកម្ពុជា។

## គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិ

គោលដៅនៃផែនការយុទ្ធសាស្ត្រ គឺដើម្បីរៀបចំឡើងវិញ និងពង្រឹងៈ

- ការគ្រប់គ្រង និងការរៀបចំកម្មវិធីត្រួតពិនិត្យការចម្លងរោគ

- ធនធានមនុស្ស
- គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ
- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បរិក្ខារ និងសម្ភារៈសម្រាប់ការត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ
- បរិស្ថាននៅក្នុងមូលដ្ឋានថែទាំសុខាភិបាល
- ការគ្រប់គ្រងសំណល់នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន
- កិច្ចសហប្រតិបត្តិការ និងការធ្វើទំនាក់ទំនង
- ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ
- ការអង្កេតឃ្លាំមើល
- សេវារោគវិនិច្ឆ័យអតិសុខុមជីវសាស្ត្រ
- ការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិកដោយប្រុងប្រយ័ត្ន
- ការស្រាវជ្រាវ និងការអភិវឌ្ឍ
- សុខភាព និងសុវត្ថិភាពការងារ
- ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពនៃសកម្មភាពត្រួតពិនិត្យការចម្លងរោគ
- គោលនយោបាយជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ និងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិបន្ទាប់នេះ

## ការរៀបចំផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា ដាក់ចេញនូវអន្តរាគមន៍ជាអាទិភាពដែលត្រូវការដើម្បីផ្តោតទៅលើផ្នែកនានានៃគោលនយោបាយជាតិដូចខាងក្រោមៈ

១. ការគ្រប់គ្រង និងការរៀបចំកម្មវិធីត្រួតពិនិត្យការចម្លងរោគ
២. ធនធានមនុស្ស
៣. គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ
៤. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បរិក្ខារ និងសម្ភារៈសម្រាប់ការត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ
៥. បរិស្ថាននៅក្នុងមូលដ្ឋានថែទាំសុខាភិបាល
៦. ការគ្រប់គ្រងសំណល់នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន
៧. កិច្ចសហប្រតិបត្តិការ និងការធ្វើទំនាក់ទំនង

៨. ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

៩. ការអង្កេតឃ្លាំមើល

១០. សេវារោគវិនិច្ឆ័យអតិសុខុមជីវសាស្ត្រ

១១. ការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិកដោយប្រុងប្រយ័ត្ន

១២. ការស្រាវជ្រាវ និងការអភិវឌ្ឍ

១៣. សុខភាព និងសុវត្ថិភាពការងារ

១៤. ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពនៃសកម្មភាពត្រួតពិនិត្យការចម្លងរោគ

១៥. គោលនយោបាយស្តីពីការត្រួតពិនិត្យការចម្លងរោគ និងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិបន្ទាប់នេះ

# ១. ការគ្រប់គ្រង និងការរៀបចំកម្មវិធីត្រួតពិនិត្យការចម្លងរោគ

## ១.១ គោលដៅយុទ្ធសាស្ត្រ

រៀបចំឡើងវិញ និងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេសនៃក្រុមត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា។

## ១.២ សកម្មភាពដែលត្រូវអនុវត្ត

ក. គាំទ្រកម្រិតនីមួយៗនៃរដ្ឋបាលដើម្បីបង្កើតក្រុមត្រួតពិនិត្យការចម្លងរោគ។

ខ. ផ្តល់ធនធានគ្រប់គ្រាន់សម្រាប់សកម្មភាពរបស់ក្រុមត្រួតពិនិត្យការចម្លងរោគ រួមមានបុគ្គលិក, បរិក្ខារការិយាល័យ, ប្រព័ន្ធទំនាក់ទំនង និងការភ្ជាប់បណ្តាញអ៊ីនធឺណិត។

គ. ផ្តល់ការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងបច្ចេកទេសសមស្របដល់ក្រុមត្រួតពិនិត្យការចម្លងរោគ នៅនាយកដ្ឋានមន្ទីរពេទ្យ តាមរយៈទស្សនកិច្ចសិក្សា, វគ្គបណ្តុះបណ្តាលខ្លីៗ, សន្និសីទអន្តរជាតិ, វគ្គបំប៉ន និងការចុះអនុវត្តជាក់ស្តែង ។ល។

ឃ. ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមត្រួតពិនិត្យការចម្លងរោគនៅគ្រប់កម្រិត អំពីរបៀបដាក់បញ្ចូល សំណើថវិកាសម្រាប់សកម្មភាពត្រួតពិនិត្យការចម្លងរោគទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។

ង. តែងតាំងក្រុមត្រួតពិនិត្យការចម្លងរោគ និងជនបង្គោលនៅគ្រប់កម្រិត, ថ្នាក់ជាតិ, ខេត្ត, ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល។

ច. ជួយគាំទ្រដល់មូលដ្ឋានសុខាភិបាលនីមួយៗ ឱ្យរាយការណ៍ពីស្ថានភាពបច្ចុប្បន្នរបស់ពួកគេ ទាក់ទងទៅនឹងការត្រួតពិនិត្យការចម្លងរោគ ដូចជាចំណុចខ្លាំង ចំណុចខ្សោយ និង របាយការណ៍ពីឧបករណ៍ សម្រាប់ការត្រួតពិនិត្យការចម្លងរោគ ដូចជាម៉ាស៊ីនអូតូក្លាវ និង ឡដុតសំរាម។

# ២. ការអភិវឌ្ឍធនធានមនុស្ស និង ការបណ្តុះបណ្តាល

## ២.១ គោលដៅយុទ្ធសាស្ត្រ

លើកកម្ពស់ជំនាញវិជ្ជាជីវៈរបស់បុគ្គលិកថែទាំសុខាភិបាល អំពីឯកទេសខាងការត្រួតពិនិត្យការចម្លង រោគ។

## ២.២ សកម្មភាពដែលត្រូវអនុវត្ត

ក. ពង្រឹងចំណេះដឹងផ្នែកការត្រួតពិនិត្យការចម្លងរោគសម្រាប់និស្សិតពេទ្យ ដោយដាក់បញ្ចូលនូវទ្រឹស្តី នៃការត្រួតពិនិត្យការចម្លងរោគនិងការប្រតិបត្តិនៅក្នុងកម្មវិធីសិក្សា ទាំងមូលដ្ឋានបណ្តុះបណ្តាលសាធារណៈ និង ឯកជន សម្រាប់:

- និស្សិតផ្នែកវេជ្ជសាស្ត្រ
- និស្សិតឱសថការី
- និស្សិតផ្នែកទន្តសាស្ត្រ
- សិស្សផ្នែកថែទាំវេជ្ជសាស្ត្រ គិលានុបដ្ឋាក-យិកា
- សិស្សបច្ចេកទេសមន្ទីរពិសោធន៍ និង ថតដោយកាំរស្មីអ៊ិច
- សិស្ស ផ្នែកព្យាបាលដោយចលនា
- សិស្សឆ្មប
- និស្សិតផ្នែកអមវេជ្ជសាស្ត្រ

ខ. ពង្រឹងសមត្ថភាពបុគ្គលិកស្តីពីការត្រួតពិនិត្យការចម្លងរោគតាមរយៈវគ្គបំប៉ន។

គ. ពង្រឹងការបណ្តុះបណ្តាលមូលដ្ឋានសម្រាប់គ្រប់បុគ្គលិកដែលបានជ្រើសរើសថ្មីទាំងអស់ ដើម្បីធានា ដល់ការប្រតិបត្តិការត្រួតពិនិត្យការចម្លងរោគត្រឹមត្រូវនៅក្នុងមូលដ្ឋានសុខាភិបាល តាមរយៈ វគ្គតម្រង់ទិសនៅពេលចាប់ផ្តើមការងារដំបូង។

ឃ. ពង្រឹងការបណ្តុះបណ្តាលបន្តសម្រាប់គ្រប់បុគ្គលិកទាំងអស់ ដែលរួមចំណែកដល់ការប្រតិបត្តិល្អ ចំពោះការត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានសុខាភិបាល។

ង. អភិវឌ្ឍ "ជំនាញត្រួតពិនិត្យការចម្លងរោគ" នៅក្នុងនាយកដ្ឋានមន្ទីរពេទ្យ និងស្ថាប័នបណ្តុះបណ្តាល

ច. អភិវឌ្ឍនិយាមអប្បបរមាសម្រាប់ស្ថាប័នបណ្តុះបណ្តាល (សាលាបណ្តុះបណ្តាលដែលបានកំណត់ក្នុង ស្រុក និងសាលាបណ្តុះបណ្តាលដែលបានកំណត់នៅក្រៅប្រទេស)

ច. កំណត់ពីវត្ថុបំណងនៃការសិក្សា និងសមត្ថភាពជំនាញផ្សេងៗសម្រាប់បុគ្គលិកផ្សេងៗ (សម្រាប់ វេជ្ជបណ្ឌិត, គិលានុបដ្ឋាក-យិកា, ក្រុមត្រួតពិនិត្យការចម្លងរោគ, អ្នកអនាម័យ ។ល។)

ឆ. រៀបចំកញ្ចប់បណ្តុះបណ្តាលថ្នាក់ជាតិសម្រាប់ការត្រួតពិនិត្យការចម្លងរោគ។

# ៣. គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ

## ៣.១ គោលដៅយុទ្ធសាស្ត្រ

ដើម្បីមានគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យការចម្លងរោគថ្មីមួយ និង នីតិវិធីប្រតិបត្តិស្តង់ដា

## ៣.២ សកម្មភាពដែលត្រូវអនុវត្ត

ក. បង្កើតក្រុមអ្នកជំនាញការខាងការត្រួតពិនិត្យការចម្លងរោគ ដើម្បីពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ។

ខ. ធានាថា គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យការចម្លងរោគឆ្លុះបញ្ចាំងពីបរិបទកម្ពុជា ទាក់ទងនឹង បរិក្ខារ, សម្ភារៈ និងស្តង់ដានៃការត្រួតពិនិត្យការចម្លងរោគ។

គ. បង្កើតប្រព័ន្ធមួយដើម្បីធានាថា គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យការចម្លងរោគត្រូវបានអនុវត្តនៅក្នុង គ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ ទាំងក្នុងវិស័យសាធារណៈ និងឯកជន និងមូលដ្ឋានដែលស្ថិតក្រោមការ គ្រប់គ្រងរបស់ក្រសួងដទៃទៀត។

ឃ. រៀបចំនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ការត្រួតពិនិត្យការចម្លងរោគ ដោយផ្អែកតាមមូលដ្ឋានសុខាភិបាល នីមួយៗ។

## ៤. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បរិក្ខារនិងសម្ភារៈត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋាន សុខាភិបាលសាធារណៈ

### ៤.១ គោលដៅយុទ្ធសាស្ត្រ

ធានាឱ្យមានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្ភារៈ និងបរិក្ខារស្តង់ដាគ្រប់គ្រាន់សម្រាប់ការប្រតិបត្តិការត្រួតពិនិត្យការចម្លងរោគ នៅក្នុងប្រទេសកម្ពុជា។

### ៤.២ សកម្មភាពដែលត្រូវអនុវត្ត

ក. រៀបចំប្រព័ន្ធមួយសម្រាប់វាយតម្លៃតម្រូវការបរិក្ខារ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅក្នុងប្រទេសដោយផ្អែកលើគោលការណ៍ ណែនាំស្តីពីការត្រួតពិនិត្យការចម្លងរោគ (អ្វីដែលមានស្រាប់ និងអ្វីខ្លះដែលមានដំណើរការអាច ប្រើបាន)

ខ. កែលម្អការប្រាស្រ័យទាក់ទងរវាងមូលដ្ឋានសុខាភិបាល និងក្រុមរោងជាងជាតិ ដើម្បីធានាការថែទាំ បរិក្ខារ។

គ. ពង្រឹងក្រុមរោងជាងជាតិនៅក្នុងក្រសួងសុខាភិបាល និង នៅថ្នាក់ខេត្តតាមរយៈការបណ្តុះបណ្តាល និងវគ្គបំប៉ន, ការពិនិត្យតួនាទីនិងភារកិច្ចឡើងវិញឱ្យបានច្បាស់លាស់ និងធានា ឱ្យមានចំនួន បុគ្គលិកគ្រប់គ្រាន់។

ឃ. ពិនិត្យឡើងវិញលើតម្រូវការបរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចុប្បន្ននៅក្នុងមូលដ្ឋានសុខាភិបាលនីមួយៗ។

ង. នាយកដ្ឋានមន្ទីរពេទ្យនឹងសម្របសម្រួលជាមួយអង្គភាពលទ្ធកម្មដើម្បីធានាថា បរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់ការត្រួតពិនិត្យការចម្លងរោគត្រូវបានទិញសម្រាប់ប្រើប្រាស់ ប្រកបដោយគុណភាពដែលអាចទទួលយកបាន។

ច. ធានាថា តម្រូវការបរិក្ខារ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជាកន្លែងសម្រាប់លាងដៃ និង បង្គន់ជាដើម ត្រូវបានដាក់បញ្ចូលទៅក្នុង ផែនការ ប្រតិបត្តិប្រចាំឆ្នាំ។

ឆ. ធានាថា បរិក្ខារទាំងអស់ដែលក្រសួងសុខាភិបាលទិញ ត្រូវតែមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ និងរួមបញ្ចូលទាំងកញ្ចប់សម្រាប់ថែទាំ ផងដែរ។

ជ. បុគ្គលិកទទួលបន្ទុកខាងការថែទាំនៅតាមមូលដ្ឋានសុខាភិបាល និងរោងជាងនីមួយៗនៅក្នុងខេត្តនីមួយៗ ត្រូវតែបានទទួលការបណ្តុះបណ្តាលក្នុងផ្នែកថែទាំ និងជួសជុលបរិក្ខារដែលប្រើប្រាស់ សម្រាប់ការងារត្រួតពិនិត្យការចម្លងរោគ។

ឈ. លើកកម្ពស់ការថែទាំ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត-បរិក្ខារ និងរបៀបប្រើប្រាស់។

ញ. ផ្តល់បរិក្ខារការពារខ្លួនគ្រប់គ្រាន់ដល់គ្រប់បុគ្គលិកសុខាភិបាលទាំងអស់។

ដ. ចាំបាច់ត្រូវមានប្រព័ន្ធជួសជុលមួយនៅក្នុងមូលដ្ឋានថែទាំសុខាភិបាលនីមួយៗ។ ត្រូវធានាថា ថវិកាចំណាយសម្រាប់ការជួសជុលមានដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ។

# ៥. បរិស្ថាននៅក្នុងមូលដ្ឋានថែទាំសុខាភិបាល

## ៥.១ គោលដៅយុទ្ធសាស្ត្រ

ដើម្បីធានាឱ្យមានបរិស្ថានស្អាតនៅក្នុងគ្រប់មូលដ្ឋានថែទាំសុខាភិបាលទាំងអស់ ដើម្បីគាំទ្រដល់ការអនុវត្តការងារត្រួតពិនិត្យការចម្លងរោគឱ្យបានល្អ។

## ៥.២ សកម្មភាពដែលត្រូវអនុវត្ត

ក. រៀបចំកន្លែងទទួលជំងឺ និងសំណាកគំរូស្តង់ដាសម្រាប់លំហូរអ្នកជំងឺនៅក្នុងអគារពិនិត្យជំងឺក្រៅ និង បន្ទប់វះកាត់នៅក្នុងមូលដ្ឋានសុខាភិបាលនីមួយៗ។

ខ. ផ្តល់ការបណ្តុះបណ្តាលអំពីអនាម័យជាមូលដ្ឋាន នៅក្នុងមូលដ្ឋានសុខាភិបាលដល់បុគ្គលិកអនាម័យ, បុគ្គលិកបោកគក់ និង បុគ្គលិកផ្ទះបាយ

គ. ផ្តល់ទឹករូប៊ីនេស្អាតដល់គ្រប់អគារនៅក្នុង មូលដ្ឋានសុខាភិបាល និង ផ្តល់កន្លែងសម្រាប់បោកគក់ ដាច់ដោយឡែកសម្រាប់អ្នកជំងឺ និង ក្រុមគ្រួសារ។

ឃ. ផ្តល់ប្រព័ន្ធសំអាតដៃគ្រប់គ្រាន់ ដូចជា កន្លែងលាងដៃ, ទឹករ៉ូប៊ីនេ, សាប៊ូ ។ល។ ដល់បុគ្គលិកសុខាភិបាល, អ្នកជំងឺ និង អ្នកមកសួរសុខទុក្ខអ្នកជំងឺ។ គួរមានយ៉ាងតិចកន្លែងលាងដៃមួយក្នុងបន្ទប់អ្នកជំងឺម្នាក់ ឬបន្ទប់ព្យាបាលមួយ។

ង. រៀបចំបង្កើត និងផ្សព្វផ្សាយរូបមន្ត/នីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ធ្វើទឹកលាងដៃដែលមានជាតិ អាល់កុល។

ច. ផ្តល់កន្លែងចម្អិនអាហារដល់អ្នកថែទាំអ្នកជំងឺ ដើម្បីជៀសវាងការដាំស្លនៅក្នុងបន្ទប់អ្នកជំងឺ។

ឆ. បង្កើតប្រព័ន្ធមួយដើម្បីអប់រំដល់អ្នកថែទាំអ្នកជំងឺអំពីការគ្រប់គ្រងសំណល់ និងមូលដ្ឋាន អនាម័យ គ្រប់ពេលដែលមាន អ្នកជំងឺថ្មីចូលមក។

ជ. បង្កើតប្រព័ន្ធមួយដើម្បីធានាថា គ្រែរបស់អ្នកជំងឺ, កម្រាលឥដ្ឋ, បន្ទប់ទឹក ត្រូវបានសំអាតរៀងរាល់ ថ្ងៃ និងរាល់ពេលដែលអ្នកជំងឺចាកចេញពីមន្ទីរពេទ្យ។ ចាំបាច់ត្រូវមានអ្នកអនាម័យគ្រប់គ្រាន់ ឬយ៉ាងហោចណាស់

ត្រូវមានម្នាក់ក្នុងមួយអាគារ និងត្រូវមានបញ្ជីផ្ទៀងផ្ទាត់ សម្រាប់សំអាតមួយដើម្បីឱ្យបុគ្គលិក អនាម័យ អនុវត្តតាម ។

ឈ. បង្កើតផ្នែកដាក់ដោយឡែក/បន្ទប់ដាច់ដោយឡែក នៅក្នុងមូលដ្ឋានសុខាភិបាលនីមួយៗ ។

ញ. ជួបប្រជុំប្រចាំខែជាមួយបុគ្គលិកអនាម័យដើម្បីពិភាក្សាដោះស្រាយបញ្ហាដែលពួកគេមាន

# ៦. ការគ្រប់គ្រងសំណល់នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន

## ៦.១ គោលដៅយុទ្ធសាស្ត្រ

ធានាថា សំណល់វេជ្ជសាស្ត្រនៅក្នុងមូលដ្ឋានសុខាភិបាល និងសហគមន៍ត្រូវបានចាត់ចែង ដោយត្រឹមត្រូវ ។

## ៦.២ សកម្មភាពដែលត្រូវអនុវត្ត

ក. ដាក់បញ្ចូលការបណ្តុះបណ្តាលសម្រាប់ការគ្រប់គ្រងសំណល់ថែទាំសុខភាព ទៅក្នុងកញ្ចប់បណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យការចម្លងរោគជាមូលដ្ឋាន ។

ខ. ផ្តល់ធុងសំរាម និងថង់ដែលមានពណ៌ផ្សេងៗដល់មូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីធ្វើការញែកសំណល់វេជ្ជសាស្ត្រសមស្របចេញពីសំណល់ទូទៅ និងចាត់ចែងសំណល់វេជ្ជសាស្ត្រ ប្រកបដោយ សុវត្ថិភាព ។

គ. បង្កើតយន្តការមួយដើម្បីធានាថា សំណល់វេជ្ជសាស្ត្រត្រូវបានធ្វើប្រព្រឹត្តកម្មដោយប្រសិទ្ធភាព និង ដោយសមស្រមដោយមូលដ្ឋានសុខាភិបាលនីមួយៗ ។

ឃ. លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសំណល់ និងសុវត្ថិភាព ។

ង. បង្កើតប្រព័ន្ធសម្របសម្រួលសម្រាប់គ្រប់គ្រងសំណល់រឹង និងរាវនៅថ្នាក់ជាតិ និងនៅក្នុងខេត្ត នីមួយៗ រវាងក្រសួងសុខាភិបាល, ក្រសួងបរិស្ថាន, មន្ទីរសុខាភិបាលខេត្ត, មន្ទីរបរិស្ថានខេត្ត និង អាជ្ញាធរមូលដ្ឋាន ដើម្បីធានាថា ស្ថាប័នទាំងនេះមានផែនការរួមគ្នាសម្រាប់គ្រប់គ្រងសំណល់ ។

ច. បង្កើតទីតាំងធ្វើប្រព្រឹត្តកម្មសំណល់វេជ្ជសាស្ត្រមួយនៅក្នុងខេត្តនីមួយៗ ដោយសម្របសម្រួលជាមួយមន្ទីរបរិស្ថានខេត្ត និងអាជ្ញាធរមូលដ្ឋាន ដើម្បីធានាថា សំណល់វេជ្ជសាស្ត្រត្រូវបានធ្វើប្រព្រឹត្តកម្មសមស្រប ។

ឆ. រៀបចំបង្កើតស្តង់ដារអប្បបរមាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់ ដូចជា ទុយោបង្ហូរ សំណល់រាវ, អាងស្តុកលាមក, មធ្យោបាយដឹកជញ្ជូន និងឡដុត នៅក្នុងមូលដ្ឋានសុខាភិបាល ។

ជ. ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់ ដល់មូលដ្ឋានសុខាភិបាលតាមខេត្ត និង ធានាដល់ការគោរពតាមគោលការណ៍ណែនាំនេះ។ បញ្ជីផ្ទៀងផ្ទាត់សម្រាប់អភិបាល និងត្រួតពិនិត្យ- តាមដានគួរត្រូវបានរៀបចំឡើង។

## ៧. សហប្រតិបត្តិការ និង ការធ្វើទំនាក់ទំនង

### ៧.១ គោលដៅយុទ្ធសាស្រ្ត

ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិដែលធ្វើការជាមួយការអភិវឌ្ឍការ ត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា ក៏ដូចជា នៅទូទាំងសកលលោក។

### ៧.២ សកម្មភាពដែលត្រូវអនុវត្ត

ក. បង្កើតបញ្ជីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ទីភ្នាក់ងារសហប្រជាជាតិ, និងសមាគមនានា ដោយមានជនបង្គោលសម្រាប់ទំនាក់ទំនង និងផ្សព្វផ្សាយដល់ក្រុមត្រួតពិនិត្យការចម្លងរោគ ទាំងអស់នៅក្នុងប្រទេស។

ខ. ចូលជាសមាជិករបស់ស្ថាប័នត្រួតពិនិត្យការចម្លងរោគអន្តរជាតិនានា ដូចជា APSIC កម្មវិធីសុវត្ថិភាពអ្នកជំងឺរបស់ WHO, សហព័ន្ធត្រួតពិនិត្យការចម្លងរោគអន្តរជាតិ ជាដើម។

គ រៀបចំការប្រជុំធំប្រចាំឆ្នាំ ស្តីពីការត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា ដើម្បីបង្កើនការយល់ដឹងនិងដើម្បីបង្ហាញពីការរីកចម្រើននៃកម្មវិធីត្រួតពិនិត្យការចម្លងរោគ

## ៨. ការត្រួតពិនិត្យតាមដាន និង ការវាយតម្លៃ

### ៨.១ គោលដៅយុទ្ធសាស្រ្ត

ធានាឱ្យមានប្រព័ន្ធត្រួតពិនិត្យតាមដាន និង វាយតម្លៃមួយដើម្បីវាស់វែងការប្រតិបត្តិការងារត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា។

### ៨.២ សកម្មភាពដែលត្រូវអនុវត្ត

ក. រៀបចំឧបករណ៍ត្រួតពិនិត្យតាមដាន និង វាយតម្លៃជាមួយការិយាល័យធានាគុណភាព ដើម្បីវាស់វែងសូចនាករអនុវត្តដូចមានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តជាតិនេះ។

ខ. ធ្វើការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិ និងចុងអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិ។

គ. បង្កើតយន្តការសម្រាប់ដោះស្រាយផ្នែកនានាដែលត្រូវការគាំទ្រ។

ឃ. ធ្វើការវាយតម្លៃមូលដ្ឋានប្រចាំឆ្នាំជាទៀងទាត់ និងដាក់បញ្ចូលរបាយការណ៍ត្រួតពិនិត្យការចម្លងរោគទៅក្នុងប្រព័ន្ធរបាយការណ៍ប្រចាំឆ្នាំថ្នាក់ជាតិរបស់មូលដ្ឋានសុខាភិបាលនីមួយៗ។

ង. ផ្ដល់ការបណ្ដុះបណ្ដាលអំពីការត្រួតពិនិត្យតាមដាន និង ការអភិបាលការត្រួតពិនិត្យការចម្លងរោគដល់បុគ្គលិកការិយាល័យធានាគុណភាព និង ក្រុមត្រួតពិនិត្យការចម្លងរោគនៅក្នុងនាយកដ្ឋានមន្ទីរពេទ្យ, មន្ទីរសុខាភិបាលខេត្ត និង ស្រុកប្រតិបត្តិ។

# ៩. ការអង្កេតឃ្លាំមើល

## ៩.១ គោលដៅយុទ្ធសាស្ត្រ

ធានាឱ្យមានទិន្នន័យបន្ថែមទៀតស្ដីពីការចម្លងរោគនៅក្នុងមន្ទីរពេទ្យនៅក្នុងមូលដ្ឋានសុខាភិបាលក្នុងប្រទេសកម្ពុជា។

## ៩.២ សកម្មភាពដែលត្រូវអនុវត្ត

ក. ធ្វើការសិក្សាជាទៀងទាត់ទៅលើការចម្លងរោគក្នុងមន្ទីរពេទ្យ នៅក្នុងមូលដ្ឋានថែទាំសុខាភិបាល ស្ដង់ដាមួយចំនួន។

ខ.បង្កើតក្រុមមួយសម្រាប់ធ្វើការស៊ើបអង្កេតការផ្ទុះការចម្លងរោគក្នុងមន្ទីរពេទ្យនៅថ្នាក់ជាតិ និង ថ្នាក់ភូមិភាគ។ ចាំបាច់ត្រូវមានសមាជិក និងតួនាទីនិងភារកិច្ចសម្រាប់ក្រុមទាំងនេះ។

គ. រៀបចំប្រព័ន្ធប្រមូលទិន្នន័យ, ប្រព័ន្ធវិភាគទិន្នន័យសម្រាប់ការចម្លងរោគក្នុងមន្ទីរពេទ្យនៅថ្នាក់ជាតិ ក៏ដូចជាថ្នាក់ខេត្ត។

ឃ. អភិវឌ្ឍជំនាញ និងសមត្ថភាពធនធានមនុស្សសម្រាប់ប្រមូល និងវិភាគទិន្នន័យស្ដីពីការចម្លងរោគ ក្នុងមន្ទីរពេទ្យ។

# ១០. សេវារោគវិនិច្ឆ័យអតិសុខុមជីវសាស្ត្រ

## ១០.១ គោលដៅយុទ្ធសាស្ត្រ

ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍អតិសុខុមជីវសាស្ត្រ ដើម្បីជួយនៅក្នុងការសិក្សាស្រាវជ្រាវ អំពីការចម្លងរោគ ដែលពាក់ព័ន្ធនឹងការថែទាំសុខភាព និងដើម្បីធានាដល់ការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិក ដោយប្រុងប្រយ័ត្ន។

## ១០.២ សកម្មភាពដែលត្រូវអនុវត្ត

ក. រួមគ្នាជាមួយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ការិយាល័យមន្ទីរពិសោធន៍ និង មន្ទីពិសោធន៍នៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដើម្បីបង្កើតមន្ទីរពិសោធន៍ អតិសុខុមជីវសាស្ត្រ ថ្នាក់ភូមិភាគនៅក្នុងខេត្តចំនួន ៤។

ខ. ពង្រីកចំនួនមន្ទីរពិសោធន៍អតិសុខុមជីវសាស្ត្រ ដែលអាចជួយនៅក្នុងការស៊ើបអង្កេតការផ្ទុះជំងឺ នៅក្នុងមន្ទីរពេទ្យ រហូតដល់ ១០ មន្ទីរពិសោធន៍ ។

គ. បណ្តុះបណ្តាលអ្នកបច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រអំពីអតិសុខុមជីវសាស្ត្រ។ ចាំបាច់ត្រូវមានយ៉ាងតិចអ្នកបច្ចេកទេសមន្ទីរពិសោធន៍ខាងអតិសុខុមជីវសាស្ត្រចំនួន ៤0នាក់ ត្រឹមឆ្នាំ ២០១៥។

ឃ. បណ្តុះបណ្តាលអ្នកឯកទេសខាងអតិសុខុមជីវសាស្ត្រ (រួមទាំងអតិសុខុមជីវសាស្ត្រគ្លីនិក) តាមរយៈកម្មវិធីសិក្សា នៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។

# ១១. ការប្រើឱសថអង់ទីប៊ីយ៉ូទីកដោយប្រុងប្រយ័ត្ន

## ១១.១ គោលដៅយុទ្ធសាស្ត្រ

ធានាឱ្យមានការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិកដោយប្រុងប្រយ័ត្ននៅក្នុងមូលដ្ឋានសុខាភិបាល។

## ១១.២ សកម្មភាពដែលត្រូវអនុវត្ត

ក. ចូលរួមនៅក្នុងការបង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគ្លីនិក ជាពិសេសពាក់ព័ន្ធនឹងប្រធានបទនៃការប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិក។

ខ. លើកទឹកចិត្តដល់គ្រូពេទ្យគ្លីនិក ឱ្យប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំស្តីពីការប្រតិបត្តិគ្លីនិក ជាពិសេសចំពោះការប្រើឱសថប្រឆាំងនឹងអតិសុខុមប្រាណ (antimicrobial)។

គ. បង្កើតប្រព័ន្ធអង្កេតឃ្លាំមើលភាពស៊ាំរបស់មេរោគនឹងឱសថអង់ទីប៊ីយ៉ូទិកនៅក្នុងមូលដ្ឋានសុខាភិបាល។

## ១២. ការស្រាវជ្រាវ និងការអភិវឌ្ឍ

### ១២.១ គោលដៅយុទ្ធសាស្ត្រ

ធានាឱ្យមានព័ត៌មានវិទ្យាសាស្ត្រច្រើនថែមទៀត អំពីការអនុវត្តការត្រួតពិនិត្យការចម្លងរោគក្នុងប្រទេសកម្ពុជា តាមរយៈការសិក្សាស្រាវជ្រាវ ។

### ១២.២ សកម្មភាពដែលត្រូវអនុវត្ត

ក. លើកទឹកចិត្តដល់សកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ និង ស្ថាប័នវេជ្ជសាស្ត្រដទៃទៀត ឱ្យធ្វើការសិក្សាស្រាវជ្រាវអំពីការចម្លងរោគដែលពាក់ព័ន្ធនឹងការថែទាំសុខភាពតាមរយៈការស្រាវជ្រាវអប់រំសម្រាប់សញ្ញាប័ត្រពេទ្យ ។

ខ. បង្កើតវេទិកាមួយសម្រាប់ចែករំលែកព័ត៌មាន/គំហើញពីការសិក្សាស្រាវជ្រាវ ។

គ. លើកទឹកចិត្តដល់ក្រុមត្រួតពិនិត្យការចម្លងរោគ និងគ្រូពេទ្យគ្លីនិក ឱ្យប្រើប្រាស់គំហើញ/ព័ត៌មាន ទាំងនេះជាភ័ស្តុតាងល្អ និងជាបន្ទាត់មូលដ្ឋានសម្រាប់អន្តរាគមន៍ និងផែនការនាពេលអនាគត ។

## ១៣. សុខភាព និង សុវត្ថិភាពការងារ

### ១៣.១ គោលដៅយុទ្ធសាស្ត្រ

ធានាដល់បរិស្ថានការងារប្រកបដោយសុវត្ថិភាព ក្នុងមូលដ្ឋានថែទាំសុខាភិបាលទាំងអស់នៃប្រទេសកម្ពុជា ។

### ១៣.២ សកម្មភាពដែលត្រូវអនុវត្ត

ក. ផ្តល់ថ្នាំបង្ការមុនពេលចូលបម្រើការងារដល់គ្រប់បុគ្គលិកសុខាភិបាលទាំងអស់ (សម្រាប់ថ្នាំបង្ការ ដែលមាន) ។

ខ. ធានាដល់ការអនុវត្តគោលការណ៍បង្ការក្រោយពេលប៉ះពាល់ (PEP) សម្រាប់មេរោគអេដស៍ និង ជំងឺឆ្លងដទៃទៀត ។

គ. បង្កើតប្រព័ន្ធអង្កេតឃ្លាំមើលសម្រាប់របួសដោយសារវត្ថុមុតស្រួចដែលប្រឡាក់មេរោគ ។

ឃ. ផ្តល់បរិក្ខារការពារខ្លួនដល់បុគ្គលិកសុខាភិបាល ។

ង. ផ្ដល់ការបណ្ដុះបណ្ដាលអំពីការប្រើបរិក្ខារការពារខ្លួនត្រឹមត្រូវដល់បុគ្គលិកសុខាភិបាល ដើម្បីធានាថា បរិក្ខារការពារខ្លួនត្រូវបានប្រើប្រាស់ដោយសមស្រប ។

## ១៤. ហិរញ្ញប្បទាន និងនិរន្តរភាពនៃសកម្មភាពត្រួតពិនិត្យការចម្លងរោគ

### ១៤.១ គោលដៅយុទ្ធសាស្ត្រ

ធានាឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ និង ប្រកបដោយនិរន្តរភាពដើម្បីចាត់ចែងកម្មវិធីត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា ។

### ១៤.២ សកម្មភាពដែលត្រូវអនុវត្ត

ក. ជួបប្រជុំពិភាក្សាជាមួយនាយកដ្ឋានផែនការ និង ព័ត៌មានសុខាភិបាល និង ការិយាល័យធានាគុណភាព ស្ដីពីការប្រើប្រាស់ មូលនិធិសមធម៌ ដើម្បីលើកកំពស់សកម្មភាពត្រួតពិនិត្យការចម្លងរោគ ។

ខ. រៀបចំសំណើសម្រាប់មូលនិធិសកលជុំទី ១០ ។

គ. គ្រប់សកម្មភាពត្រួតពិនិត្យការចម្លងរោគទាំងអស់ត្រូវតែដាក់បញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ។

## ១៥. ការកែសម្រួលគោលនយោបាយស្ដីពីការត្រួតពិនិត្យការចម្លងរោគ

### ១៥.១ គោលដៅយុទ្ធសាស្ត្រ

ធានាថា គោលនយោបាយត្រូវបានកែសម្រួលឡើងវិញក្រោយរយៈពេល ៥ ឆ្នាំ ។

### ១៥.២ សកម្មភាពដែលត្រូវអនុវត្ត

បង្កើតក្រុមការងារមួយ ដើម្បីកែសម្រួលឡើងវិញនូវគោលនយោបាយស្ដីពីការត្រួតពិនិត្យការចម្លងរោគ ។

# សកម្មភាពអាទិភាពនៃផែនការយុទ្ធសាស្ត្រត្រួតពិនិត្យការចម្លងរោគ

| ១-ការគ្រប់គ្រង និងការរៀបចំកម្មវិធីត្រួតពិនិត្យ ការចម្លងរោគ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ១.១ | ជួយគាំទ្រ ដល់មូលដ្ឋានរដ្ឋបាលគ្រប់ជាន់ថ្នាក់ ក្នុងការតែងតាំងក្រុមការងារត្រួតពិនិត្យការចម្លងរោគនៅគ្រប់កម្រិត នៅក្នុងប្រទេសកម្ពុជា | 0 | មានក្រុមត្រួតពិនិត្យការចម្លង រោគទូទាំងប្រទេស | X | | | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត |
| ១.២ | ជួយគាំទ្រ ក្រុមការងារត្រួតពិនិត្យការចម្លងរោគនៅគ្រប់កម្រិតក្នុងការ រៀបចំផែនការថវិកា និង សំភារៈ<br>ដើម្បីដាក់បញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ( ក្រុមត្រួត ពិនិត្យការចម្លង រោគនៅថ្នាក់ ខេត្ត និងមន្ទីរ ពេទ្យជាតិ គ្លីនិកឯកជន) | 0 | -មានផែនការថវិកា<br>-មានសំភារៈការិយាល័យនៅថ្នាក់៖<br>o ខេត្ត មន្ទីរពេទ្យជាតិ គ្លីនិកឯកជន<br>o ស្រុកប្រតិបត្តិ ម.ពេទ្យបង្អែក គ្លីនិកឯកជន | X | X<br>X | X<br>X | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរពេទ្យជាតិ<br>-មន្ទីរសុខាភិបាលខេត្ត |
| ១.៣ | ផ្តល់ការបណ្តុះបណ្តាលជំនាញគ្រប់គ្រងសម្រាប់ក្រុមត្រួតពិនិត្យការចម្លងរោគ ថ្នាក់ជាតិនាយកដ្ឋានមន្ទីរពេទ្យ | 0 | បណ្តុះបណ្តាលជំនាញគ្រប់គ្រង | X | X | | | | | -ក្រុមការងារជាតិ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១.៤ | លើកកំពស់សមត្ថភាពបញ្ចូលថវិកាសម្រាប់សកម្មភាព ត្រួតពិនិត្យការចម្លងរោគ ទៅក្នុងផែនការ ប្រតិបត្តិប្រចាំឆ្នាំ ដោយក្រុមត្រួតពិនិត្យការចម្លង រោគនីមួយៗ | 0 | -គ្រប់ក្រុមត្រួតពិនិត្យ ការចម្លងរោគ | X | X | X | X | X | X | -នាយកដ្ឋានមន្ទីរពេទ្យ<br>-នាយកដ្ឋានផែនការ<br>- មន្ទីរសុខាភិបាលខេត្ត<br>-អង្គការដៃគូអភិវឌ្ឍ |

| ២-ការអភិវឌ្ឍធនធានមនុស្ស និង ការបណ្តុះបណ្តាល | | **ទិន្នន័យមូលដ្ឋាន** | **គោលដៅចំណុច** | **បន្ទាត់ពេលវេលា** | | | | | | **អ្នកទទួលខុសត្រូវ** |
|---|---|---|---|---|---|---|---|---|---|---|
| **ល.រ** | **សកម្មភាព** | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ២.១ | លើកទឹកចិត្ត ធ្វើយ៉ាងណាឱ្យទ្រឹស្តីនិងការអនុវត្តការត្រួតពិនិត្យការចម្លងរោគ ត្រូវបានដាក់បញ្ចូល និង ត្រូវបានពង្រឹងបន្ថែមនៅក្នុងកម្មវិធីសិក្សា សម្រាប់គ្រឹះស្ថានសិក្សា វិស័យ សុខាភិបាលសាធារណៈ និង ឯកជន | | -សបថទវ.-សាលាភូមិភាគ (សមសភ) សអ. ចេនឡា និង វសុខម ពង្រឹងការត្រួតពិនិត្យការ ចម្លង ក្នុងកម្មវិធីសិក្សា<br>-សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បានដាក់បញ្ចូល ការពិនិត្យការ ចម្លងក្នុង កម្មវិធីសិក្សា | | X | X | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-នាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស |
| ២.២ | អភិវឌ្ឍជំនាញបច្ចេកទេសត្រួតពិនិត្យការ ចម្លងរោគ ដល់ក្រុមត្រួតពិនិត្យ ការចម្លងរោគនៅនាយកដ្ឋានមន្ទីរពេទ្យតាមរយៈវគ្គសិក្សាខ្លីៗ | | -ក្រ.ត្រួតពិនិត្យកាចម្លងរោគ ១២នាក់ | X | X | X | | | | -អង្គការសុខភាពពិភពលោក និង ដៃគូអភិវឌ្ឍ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២.៣ | អភិវឌ្ឍមន្ទីរពេទ្យ(Center of excellence) គំរូ សម្រាប់ បណ្តុះបណ្តាលការត្រួតពិនិត្យការចម្លងរោគ។ | 0 | -ម.ពេទ្យ ៦ជា ម.ព.គំរូ លើការត្រួពិនិត្យការចម្លងរោគ | 1 | 1 | 1 | 1 | 1 | 1 | -នាយកដ្ឋានមន្ទីរពេទ្យ<br>-អង្គការសុខភាពពិភពលោក ដៃគូអភិវឌ្ឍន៍ |
| ២.៤ | រៀបចំកញ្ចប់បណ្តុះបណ្តាល និងធ្វើការ បណ្តុះបណ្តាល សម្រាប់ការត្រួតពិនិត្យ ការចម្លងរោគដែលរួមបញ្ចូលទាំង ការគ្រប់គ្រងសំណល់ពីការ ថែទាំសុខភាព ( មិនទាន់កំណត់ច្បាស់ចំនួនម៉ូឌុល) ។ | 0 | -ម៉ូឌុលមូលដ្ឋានបានបង្កើត<br>-ម៉ូឌុលផ្សេងទៀតត្រូវបានបញ្ចប់ | X | X | | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-អង្គការសុខភាពពិភពលោក<br>-អង្គការ ដៃគូអភិវឌ្ឍន៍<br>-ក្រុមការងារថ្នាក់ជាតិ |

| ៣- គោលការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ | | **ទិន្នន័យមូលដ្ឋាន** | **គោលដៅចំណុច** | **បន្ទាត់ពេលវេលា** | | | | | | **អ្នកទទួលខុសត្រូវ** |
|---|---|---|---|---|---|---|---|---|---|---|
| **ល.រ** | **សកម្មភាព** | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ៣.១ | កែសម្រួលឯកសារស្តីពីសមាជិកភាព និង តួនាទី ភារកិច្ច របស់ក្រុមអ្នកជំនាញខាងការត្រួតពិនិត្យ ការចម្លងរោគដើម្បីពិនិត្យឡើងវិញលើគោល ការណ៍ណែនាំជាតិស្តីពីការត្រួតពិនិត្យការចម្លងរោគ ( ក្រុមមួយមាន សមាជិក៥នាក់) | មានក្រុម១ សមាជិក៥ នាក់ | -ក្រុមការងារមានតួនាទី និងភារៈកិច្ចច្បាស់លាស់ត្រូវបានបង្កើត | | | X | | | X | -នាយកដ្ឋានមន្ទីរពេទ្យ |
| ៣.២ | កែសម្រួលឯកសារគោលការណ៍ណែនាំជាតិស្តីពី ការត្រួតពិនិត្យការចម្លងរោគដើម្បីសម្របឱ្យកាន់តែប្រសើរទៅតាមបរិបទកម្ពុជា | កំពុងរៀបចំ | -មានគោលការណ៍ណែនាំដើម្បីអនុវត្ត | X | | | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-ក្រុមការងារជាតិ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ដើម្បីអនុវត្ត | | -មានគោលការណ៍ណែនាំថ្មី ប្រសិនបើចាំបាច់ | | | | X | | | |
| ៣.៣ | ចែកចាយគោលការណ៍ណែនាំជាតិស្តីពីការត្រួត ពិនិត្យការចម្លងរោគដល់គ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ ទាំងឯកជន ទាំងសាធារណៈ ទាំងក្នុងទាំងក្រៅការគ្រប់គ្រងរបស់ ក្រសួងសុខាភិបាល | 0 | -គោលការណ៍ណែនាំ ត្រូវបានចែកចាយរួចរាល់ | X | | | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-ក្រុមការងារជាតិ |

| ៤- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បរិក្ខារនិងសម្ភារៈត្រួតពិនិត្យការចម្លងរោគនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ៤.១ | បង្កើតបញ្ជីផ្ទៀងផ្ទាត់សាមញ្ញមួយសម្រាប់ វាយតម្លៃប្រព័ន្ធត្រួតពិនិត្យការចម្លងរោគ ដូចជា ស្តង់ដាអគារ កន្លែងលាងដៃដែលមានដំណើរការ, ធ្នាំងរម្ងាប់មេរោគអូតូក្លាវដែលមានដំណើរ ការ, ប្រព័ន្ធទឹក ស្អាត, ឡដុតដែលមានដំណើរការ និង បង្គន់អនាម័យ ។ល។ នៅក្នុង មូលដ្ឋានសុខាភិបាលនីមួយៗ | គ្មាន | -មានបញ្ជីផ្ទៀងផ្ទាត់ សម្រាប់ប្រើប្រាស់ | | | X | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត<br>-ក្រុមការងារជាតិ |
| ៤.២ | ចាប់ផ្តើមធ្វើការវាយតម្លៃលើខ្លួនឯងដោយ មូលដ្ឋានសុខាភិបាលនីមួយៗ | គ្មាន | មូលដ្ឋានសុខាភិបាល១០០ ភាគរយ | | | X | X | | | -គ្រប់មូលដ្ឋានថែទាំសុខាភិបាល<br>- នាយកដ្ឋានមន្ទីរពេទ្យ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤.៣ | តែងតាំងជនបង្គោលម្នាក់សម្រាប់ថែទាំបរិក្ខារ ត្រួតពិនិត្យការចម្លងរោគ និងត្រូវមានតួនាទីនិងភារកិច្ច ច្បាស់នៅក្នុងរោងជាងជាតិ ដើម្បីឱ្យក្រុមត្រួត ពិនិត្យការចម្លងរោគមកពីមូលដ្ឋានសុខាភិបាល នីមួយៗ អាច ទាក់ទងនិងតាមដានបន្ត | 0 | -ជនបង្គោលត្រូវបានតែងតាំង នៅក្នុងរោងជាងជាតិ- -ជនបង្គោលត្រូវបានធ្វើបច្ចុប្បន្នភាព បើចាំបាច់ | X | X | X | X | X | X | - នាយកដ្ឋានមន្ទីរពេទ្យ |
| ៤.៤ | រៀបចំបញ្ជីស្តង់ដាសម្រាប់បរិក្ខារត្រួតពិនិត្យការ ចម្លងរោគ រួមជាមួយការថែទាំ និងរបៀប ប្រើប្រាស់បរិក្ខារទាំងនេះ និងត្រូវធានាថា អង្គភាពលទ្ធកម្មមានភ្ជាប់ជាមួយបញ្ជីស្តង់ដា ជាអនុសាសន៍ | 0 | -មានបញ្ជី ១ស្តង់ដា | X | X | | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-ក្រុមការងារជាតិ<br>-អង្គការសុខភាពពិភពលោក<br>-អង្គការ ដៃគូអភិវឌ្ឍន |

| ៥- បរិស្ថាននៅក្នុងមូលដ្ឋានសុខាភិបាល | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ៥.១ | រៀបចំគំរូប្រព័ន្ធទទួលនិង បែងចែកជំងឺនៅក្នុងមូលដ្ឋាន សុខាភិបាល (ជារូបភាព ប្លង់អគារ) | គ្មាន | -គំរូប្រព័ន្ធទទួលជំងឺត្រូវបានបង្កើត (ជារូបភាព ប្លង់អគារ)<br>-ប្រព័ន្ធទទួលជំងឺ តាមប្លង់គំរូត្រូវបានដំណើរការ | X | 30% | 50% | 70% | 90% | 100% | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត<br>-ក្រុមការងារជាតិ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៥.២ | ផ្តល់ទឹកស្អាតដល់គ្រប់មូលដ្ឋានសុខាភិបាល | មិនដឹង | -ស្វែងរកថវិកា<br>-មូលដ្ឋានសុខាភិបាលទាំងអស់ | X | 30% | 50% | 70% | 90% | 100% | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត<br>-ដៃគូអភិវឌ្ឍ |
| ៥.៣ | ផ្តល់ប្រព័ន្ធសម្អាតដៃគ្រប់គ្រាន់ ដូចជា កន្លែងលាងដៃ, ទឹករ៉ូប៊ីនេ, សាប៊ូ ។ល។ | មិនដឹង | -ស្វែងរកថវិកា<br>-មូលដ្ឋានសុខាភិបាលទាំងអស់ | X | 30% | 50% | 70% | 90% | 100% | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត<br>-ដៃគូអភិវឌ្ឍ |
| ៥.៤ | រៀបចំផលិតសម្ភារៈអប់រំសុខភាពសម្រាប់អ្នក ថែទាំអ្នកជំងឺ និង អ្នកមកសួរសុខទុក្ខអ្នកជំងឺ ទាក់ទងនឹងការត្រួតពិនិត្យការចម្លងរោគ | គ្មាន | -ស្វែងរកថវិកា<br>-មានសម្ភារៈអប់រំ | X | X | X | X | X | X | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត<br>-ដៃគូអភិវឌ្ឍ |
| ៥.៥ | ពិនិត្យឡើងវិញជាលម្អិតស្តង់ដារសម្រាប់អគារ នៅក្នុងមូលដ្ឋានសុខាភិបាលដែលរួមមាន រចនាសម្ព័ន្ធត្រួតពិនិត្យការចម្លងរោគស្តង់ដារ (បន្ទប់ដាច់ដោយឡែក គួរដាក់បញ្ចូលក្នុង ផែនការនេះផងដែរ) | គ្មាន | -ស្វែងរកថវិកា<br>-ស្តង់ដារលម្អិតត្រូវបានពិនិត្យឡើងវិញ | X | X | | | | | -នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត<br>-ក្រុមការងារជាតិ |

| ៦- ការគ្រប់គ្រងសំណល់នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និង ឯកជន | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ៦.១ | ផ្គត់ផ្គង់ធុងសំរាម.ថង់ និងប្រអប់សុវត្ថិភាពដែលមានគំរូស្តង់ដា ដល់មូលដ្ឋានសុខាភិបាល សាធារណៈ និង ឯកជន | ៤ | -ផ្គត់ផ្គង់ធុងសំរាម និងថង់ដល់ មូលដ្ឋាន | 30% | 40% | 50% | 60% | 70% | 80% | -ក្រុមការងារ-សំណល់<br>-នាយកដ្ឋានមន្ទីរពេទ្យ<br>-ដៃគូអភិវឌ្ឍ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៦.២ | ស្វែងរកដៃគូ អភិវឌ្ឍ និង ចាប់ផ្តើមរៀបចំបង្កើតសម្ភារៈ អប់រំសុខភាព និងឯកសារសង្ខេបពីប្រកាសស្តីពីការគ្រប់គ្រងសំណល់ ថែទាំសុខភាព (សម្រាប់ប្រជាជនទូទៅ និង បុគ្គលិកសុខាភិបាល ) | មិនដឹង | -សម្ភារៈ អប់រំ និងឯកសារត្រូវបានបង្កើត | | X | | | | | -ក្រុមការងារ-សំណល់<br>-នាយកដ្ឋានមន្ទីរពេទ្យ<br>-ដៃគូអភិវឌ្ឍ |
| ៦.៣ | ចែកចាយ សម្ភារៈ អប់រំសុខភាព ស្តីពីការគ្រប់គ្រងសំណល់ពីការថែទាំសុខភាព (សម្រាប់ប្រជាជនទូទៅ និង បុគ្គលិកសុខាភិបាល ) ដល់ គ្រប់មូលដ្ឋានសុខាភិបាលឯកជន និងសាធារណៈ | | -សម្ភារៈ អប់រំ និងឯកសារត្រូវបានចែកចាយ | | X | X | | | | -ក្រុមការងារ-សំណល់<br>-នាយកដ្ឋានមន្ទីរពេទ្យ<br>-ដៃគូអភិវឌ្ឍ |
| ៦.៤ | ផ្តល់ឡដុតដល់គ្រប់មន្ទីរពេទ្យបង្អែកទាំងអស់ | មិនមានចំនួនច្បាស់ | មន្ទីរពេទ្យបង្អែកទាំងអស់មានឡដុត (ពាក់ព័ន្ធទៅនិងមូលនិធិសាកល) | 24 | ? | ? | ? | ? | ? | -នាយកដ្ឋានមន្ទីរពេទ្យ<br>-ដៃគូអភិវឌ្ឍ<br>-មូលនិធិសាកល |
| ៦.៥ | ស្វែងរកដៃគូអភិវឌ្ឍបង្កើតឡដុតឯកជននៅក្នុងខេត្តគោលដៅមួយចំនួន សម្រាប់ធ្វើប្រព្រឹត្តកម្មសំណល់ វេជ្ជសាស្រឱ្យបានត្រឹមត្រូវ | មិនមាន | ឡដុតឯកជននៅក្នុងខេត្តចំនួន៤ | 0 | 0 | 1 | 1 | 1 | 1 | នាយកដ្ឋានមន្ទីរពេទ្យ<br>-មន្ទីរសុខាភិបាលខេត្ត |

| ៧- សហប្រតិបត្តិការ និង ការធ្វើទំនាក់ទំនង | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ៧.១ | បង្កើតបញ្ជីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរ ជាតិ, ទីភ្នាក់ងារសហប្រជាជាតិ, និងសមាគម នានាដោយមានជនបង្គោលសម្រាប់ ទំនាក់ទំនង និងផ្សព្វផ្សាយដល់ក្រុមត្រួតពិនិត្យការចម្លងរោគ ទាំងអស់នៅក្នុងប្រទេស។ | គ្មាន | បញ្ជីបានបង្កើត | X | | | | | | នាយកដ្ឋានមន្ទីរពេទ្យ ក្រុមការងារជាតិ |
| ៧.២ | ចូលជាសមាជិករបស់ស្ថាប័នត្រួតពិនិត្យការចម្លង រោគអន្តរជាតិនានា ដូចជា APSIC កម្មវិធីសុវត្ថិ ភាពអ្នកជំងឺរបស់ WHO, សហព័ន្ធត្រួតពិនិត្យ ការចម្លងរោគអន្តរជាតិ ជាដើម។ | គ្មាន | ចូលជាសមាជិករបស់ស្ថាប័នត្រួតពិនិត្យការចម្លងរោគអន្តរជាតិនានា ដូចជា APSIC កម្មវិធីសុវត្ថិភាពអ្នកជំងឺរបស់ WHO, | | X | | | | | នាយកដ្ឋានមន្ទីរពេទ្យ ក្រុមការងារជាតិ អង្គការសុខភាពពិភពលោក |
| ៧.៣ | រៀបចំការប្រជុំបូកសរុបលទ្ធផល និងធ្វើផែនការប្រចាំឆ្នាំស្តីពីការត្រួតពិនិត្យការចម្លងរោគនៅក្នុងប្រទេសកម្ពុជា | គ្មាន | ប្រជុំធំប្រចាំឆ្នាំ | X | X | X | X | X | X | នាយកដ្ឋានមន្ទីរពេទ្យ |

| ៨- ការត្រួតពិនិត្យតាមដាន និង ការវាយតម្លៃ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ៨.១ | រៀបចំបង្កើតឧបករណ៍សម្រាប់ត្រួតពិនិត្យតាម ដាន និងវាយតម្លៃជាមួយការិយាល័យធានា គុណភាព និង URC | | ឧបករណ៍សម្រាប់ត្រួតពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីត្រួតពិនិត្យការចម្លងរោគ<br><br>ឧបករណ៍សម្រាប់ត្រួតពិនិត្យតាមដាន និងវាយតម្លៃការត្រួតពិនិត្យការចម្លងរោគក្នុងមូលដ្ឋានសុខាភិបាល | X<br><br><br> | <br><br>X | | | | | នាយកដ្ឋានមន្ទីរពេទ្យ<br>អង្គការសុខភាពពិភពលោក<br>អង្គការដៃគូ |
| ៨.២ | ត្រួតពិនិត្យ តាមដាននិង វាយតម្លៃ កម្មវិធីត្រួតពិនិត្យការចម្លងរោគ | | ចុះត្រួតពិនិត្យ តាមដាននិងវាយតម្លៃ ចំនួន ២ ដង | | | X | | | X | នាយកដ្ឋានមន្ទីរពេទ្យ<br>អង្គការសុខភាពពិភពលោក<br>អង្គការដៃគូ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៨.៣ | ត្រួតពិនិត្យ តាមដាននិង វាយតម្លៃ ការត្រួតពិនិត្យការចម្លងរោគ ក្នុងមូលដ្ឋានសុខាភិបាល | | ចុះត្រួតពិនិត្យ តាមដាននិង វាយតម្លៃ គ្រប់មន្ទីរពេទ្យជាតិ ខេត្ត បង្អែក ចំនួន ១ ដង យ៉ាងតិច | | | 20 | 20 | 20 | 20 | នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរសុខាភិបាលខេត្ត ការិយាល័យស្រុកប្រតិបត្ត អង្គការដៃគូ |

| ល.រ | ៩- ការអង្កេតឃ្លាំមើល<br>សកម្មភាព | ទិន្នន័យមូលដ្ឋាន<br>២០០៩ | គោលដៅចំណុច | បន្ទាត់ពេលវេលា<br>២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ៩.១ | រៀបចំការអង្កេតឃ្លាំមើល ឬការសិក្សាស្រាវជ្រាវពីការចម្លងរោគក្នុងមន្ទីរពេទ្យ និងភាពស៊ាំ របស់មេរោគនឹងថ្នាំ នៅក្នុងមូលដ្ឋានសុខភាពមួយចំនួន | មិនដឹង | ធ្វើការអង្កេតឃ្លាំមើល ឬការសិក្សាស្រាវជ្រាវចំនួន ១០ | | 2 | 2 | 2 | 2 | 2 | នាយកដ្ឋានមន្ទីរពេទ្យ អង្គការដៃគូ ន.ដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ៩.២ | ពង្រឹងសមត្ថភាពក្រុមស៊ើបអង្កេតការផ្ទុះជម៉ឺថ្នាក់ជាតិ ដើម្បីជួយ នៅពេលមានការផ្ទុះឡើងនូវការចម្លង រោគក្នុងមន្ទីរពេទ្យ | គ្មាន | ក្រុមថ្នាក់ជាតិមួយ ត្រូវបាន ពង្រឹង | X | | | | | | នាយកដ្ឋានមន្ទីរពេទ្យ អង្គការដៃគូ ន.ដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៩.៣ | បង្កើតមូលដ្ឋានទិន្នន័យសម្រាប់ការចម្លងរោគ ក្នុងមន្ទីរពេទ្យនៅថ្នាក់ជាតិ | គ្មាន | កំណត់ប្រភេទការចម្លងរោគដែលត្រូវដាក់បញ្ចូលក្នុងមូលដ្ឋានទិន្នន័យ | X | | | | | | នាយកដ្ឋានមន្ទីរពេទ្យ<br>អង្គការដៃគូ<br>ន.ដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| | | | បង្កើតរបៀបប្រមូលទិន្នន័យ និងធ្វើការសាកល្បង | | X | | | | | |
| | | | ចាប់ផ្តើមប្រមូលទិន្នន័យ | | | X | | | | |

| ១០- សេវារោគវិនិច្ឆ័យអតិសុខុមជីវសាស្ត្រ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ១០.១ | រួមគ្នាជាមួយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ការិយាល័យមន្ទីរពិសោធន៍ និង វិទ្យាស្ថានជាតិសុខភាពសាធារណៈ បង្កើតមន្ទីរ ពិសោធន៍អតិសុខុមជីវសាស្ត្រ ថ្នាក់ ភូមិភាគ នៅក្នុងខេត្តចំនួន ៤ | មន្ទីរពិសោធន៍ អតិសុខុមជីវសាស្ត្រ ខេត្តកំពង់ចាម១ | - មន្ទីរពិសោធន៍អតិសុខុមជីវសាស្ត្រ ថ្នាក់ភូមិភាគ ចំនួន ៤ ឬច្រើនជាងនេះ:<br>-បាត់ដំបង<br>-តាកែវ<br>-សៀមរាប<br>-ខេត្តផ្សេងៗ | 1 | 1 | 1 | 1 | 1 | 1 | នាយកដ្ឋានមន្ទីរពេទ្យ<br>ន.ដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង<br>វិទ្យាស្ថានជាតិសុខភាពសាធារណៈ:<br>ការិយាល័យមន្ទីរពិសោធន៍<br>មន្ទីសុខាភិបាលខេត្ត<br>អង្គការសុខភាពពិភពលោក |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១០.២ | រួមគ្នាជាមួយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងការិយាល័យ មន្ទីរពិសោធន៍ អភិវឌ្ឍធនធាន មនុស្សផ្នែកអតិសុខុមជីវសាស្ត្រ សម្រាប់មន្ទីរ ពិសោធន៍អតិសុខុមជីវសាស្ត្រ ថ្នាក់ ភូមិភាគ | | បណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធន៍ ខេត្តបាត់ដំបង<br>បណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធន៍ ខេត្តតាកែវ<br>បណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធន៍ ខេត្តសៀមរាប<br>បណ្តុះបណ្តាលបុគ្គលិកមន្ទីរពិសោធន៍ ខេត្តដទៃ | X | X | X | X | X | X | នាយកដ្ឋានមន្ទីរពេទ្យ<br>ន.ដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង<br>វិទ្យាស្ថានជាតិសុខភាពសាធារណៈ<br>ការិយាល័យមន្ទីរពិសោធន៍<br>មន្ទីសុខាភិបាលខេត្ត<br>អង្គការសុខភាពពិភពលោក |
| ១០.៣ | អភិវឌ្ឍអ្នកឯកទេសខាងអតិសុខុមជីវសាស្ត្រ | | មានអ្នកឯកទេសខាងអតិសុខុមជីវសាស្ត្រ៤នាក់ | | | | 2 | | 2 | នាយកដ្ឋានមន្ទីរពេទ្យ<br>អង្គការដៃគូ<br>ន.ធនធានមនុស្ស<br>សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |

| ១១- ការប្រើឱសថអង់ទីប៊ីយ៉ូទិកដោយប្រុងប្រយ័ត្ន | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ១១.១ | ចូលរួមនៅក្នុងការបង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគ្លីនិក ជាពិសេស ពាក់ព័ន្ធនឹង ប្រធានបទនៃការ ប្រើប្រាស់ឱសថអង់ទីប៊ីយ៉ូទិក | មិនដឹង | មានគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងគ្លីនិក | | X | | | | | នាយកដ្ឋានមន្ទីរពេទ្យ |

| ១២- ការស្រាវជ្រាវ និងការអភិវឌ្ឍ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ១២.១ | រៀបចំកិច្ចប្រជុំជាមួយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដើម្បីដាក់បញ្ចូលការត្រួតពិនិត្យការចម្លងរោគជាមុខវិជ្ជាស្រាវជ្រាវសម្រាប់ ការធ្វើនិក្ខេបបទរបស់និស្សិត | | ប្រជុំជាមួយសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | X | | | | | | នាយកដ្ឋានមន្ទីរពេទ្យ សវស. អង្គការសុខភាពពិភពលោក |
| ១២.២ | ធ្វើការបង្ហាញពី លទ្ធផលនៃការសិក្សា ស្រាវជ្រាវថ្មីៗ ទាក់ទងទៅនឹង ការត្រួតពិនិត្យការ ចម្លងរោគ នៅក្នុងកិច្ចប្រជុំទូទាំងប្រទេសប្រចាំឆ្នាំ | | កិច្ចប្រជុំទូទាំងប្រទេសប្រចាំឆ្នាំ | | X | X | X | X | X | នាយកដ្ឋានមន្ទីរពេទ្យ សវស. អង្គការសុខភាពពិភពលោក |

| ១៣- សុខភាព និង សុវត្ថិភាពការងារ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ១៣.១ | បង្កើតមូលដ្ឋានទិន្នន័យសម្រាប់របាយការណ៍ អំពីរបួសដោយសារវត្ថុមុតស្រួច | | បង្កើតរបៀបប្រមូលទិន្នន័យ និងធ្វើការសាកល្បង<br>ចាប់ផ្ដើមប្រមូលទិន្នន័យ | | X | X | | | | នាយកដ្ឋានមន្ទីរពេទ្យ នាយកដ្ឋានផែនការ |
| ១៣.២ | សហការជាមួយកម្មវិធីជាតិផ្ដល់ថ្នាំបង្ការ និង ដៃគូអភិវឌ្ឍផ្សេងៗទៀត ដើម្បីបង្កើត កម្មវិធីផ្ដល់ថ្នាំបង្ការដល់បុគ្គលិក | | -កិច្ចប្រជុំជាមួយកម្មវិធីចាក់ថ្នាំបង្ការនិង ដៃគូរ | X | X | X | | | | នាយកដ្ឋានមន្ទីរពេទ្យ |

| ១៤- ហិរញ្ញប្បទាន និងនិរន្តរភាពនៃសកម្មភាពត្រួតពិនិត្យការចម្លងរោគ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ១៤.១ | ធ្វើការជាមួយ WHO/CAM និង ក្រុងស៊ុលតង់ដើម្បីព្រាងសំណើមូលនិធិសកល សម្រាប់ការត្រួតពិនិត្យការចម្លងរោគ | | សំណើមូលនិធិសកលជុំទី១០ | X | | | | | | នាយកដ្ឋានមន្ទីរពេទ្យ អង្គការសុខភាពពិភពលោក.... |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៤.២ | សម្របសម្រួលរវាងនាយកដ្ឋានផែនការ, នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង, នាយកដ្ឋាន មន្ទីរពេទ្យ និង WHO ដើម្បីបំភ្លឺអំពីការដាក់បញ្ចូលថវិកាត្រួតពិនិត្យការចម្លងរោគ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ | | ការដាក់បញ្ចូលថវិកាត្រួតពិនិត្យការចម្លងរោគ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវបានធ្វើការប្រជុំនិងចែកចាយ | X | | | | | | នាយកដ្ឋានមន្ទីរពេទ្យ<br>នាយកដ្ឋានផែនការ<br>អង្គការសុខភាពពិភពលោក.... |

| ១៥- ការកែសម្រួលគោលនយោបាយស្តីពីការត្រួតពិនិត្យការចម្លងរោគ | | ទិន្នន័យមូលដ្ឋាន | គោលដៅចំណុច | បន្ទាត់ពេលវេលា | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|
| **ល.រ** | **សកម្មភាព** | ២០០៩ | | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | |
| ១៥.១ | បង្កើតក្រុមការងារមួយដែលមានសមាជិក និងតួនាទី និងភារកិច្ច ដើម្បីកែសម្រួលគោល នយោបាយស្តីពីការត្រួតពិនិត្យការចម្លងរោគ ប្រសិនបើនៅពេលចាំបាច់។ | | -ក្រុមការងារមួយត្រូវបានបង្កើត<br>-កែ សម្រួលគោលនយោបាយ | X | | | | | X | នាយកដ្ឋានមន្ទីរពេទ្យ<br>អង្គការសុខភាពពិភពលោក.<br>ក្រុមការងារជាតិ |